ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍

## ស្តីពី

## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមេសា ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមេសាឆ្នាំ២០១៦នេះ ក្រសួងបានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧។ អង្គសន្និបាតបានកត់សម្គាល់ថា រយៈពេល៣ឆ្នាំចុងក្រោយនេះ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងខ្លាំងលើផលិតកម្មកសិកម្ម។ ជាក់ស្តែង នៅឆ្នាំ២០១៥កន្លងទៅនេះ យើងបានទទួលរងនូវបាតុភូតគ្រោះធម្មជាតិ គឺគ្រោះរាំងស្ងួត ដែលជាបច្ច័យអាក្រក់រាំងស្ទះដល់ដំណើរការដាំដុះរបស់កសិករ។ តែទោះជាយ៉ាងនេះក្តី វិស័យកសិកម្មរបស់យើងក៏នៅមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលក្នុងនោះ យើងទទួលបានផលិតផលស្រូវសរុបក្នុងបរិមាណជាង៩.៣៣០.០០០តោន និងអតិរេកស្បៀងប្រមាណ៤.៦៤០.០០០តោនស្រូវ ឬគិតជាអង្ករជិត៣លានតោន ដែលនេះជាជោគជ័យមួយដ៏ធំសម្រាប់កសិកម្មយើង។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តន៍នៃយន្តូបនីយកម្មកសិកម្ម។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ កន្លងមកនេះ ការភ្ជួររាស់ដោយគ្រឿងយន្តមានប្រមាណ៨៤ភាគរយ។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ លើសពីនេះ តំបន់មួយចំនួននៃបណ្តាខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល សៀមរាប បាត់ដំបង និងខេត្តស្ទឹងត្រែង បាននិងកំពុងប្រឈមនឹងការខ្វះចំណីសត្វ និងខ្វះទឹក ដែលជាកត្តាធ្វើឱ្យសត្វស្រេស ថមថយសុខភាព ឈឺ និងស្លាប់ សរុបប្រមាណ១៩៩ក្បាល ដែលភាគច្រើនជាសត្វគោ-ក្របី។ ស្ថិតក្នុងស្ថានភាពចំពោះមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងចាត់វិធានការជួយសង្គ្រោះអាយុជីវិតសត្វរបស់ប្រជាពលរដ្ឋ និងផ្តល់កិច្ចអន្តរាគមន៍សុខភាពសត្វនៅតាមតំបន់ប្រឈមទាំងនោះតាមគ្រប់មធ្យោបាយដូចជា ឧបករណ៍ សម្ភារ បរិក្ខារបសុពេទ្យផ្សេងៗ និងបានរៀបចំយន្តការឆ្លើយតបបន្ទាន់។ សកម្មភាពគួរកត់សម្គាល់មួយទៀត គឺមន្ត្រីជំនាញរដ្ឋបាលព្រៃឈើបានសហការជាមួយគណៈកម្មការជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតាមអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ តាមស្មារតីនៃសេចក្តីសម្រេច លេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានសម្រាប់ខែមេសា ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវ

នៅក្នុងឆ្នាំ២០១៥-២០១៦នេះ ស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងភ្លៀងធ្លាក់ច្រើននៅចុងរដូវវស្សា។ ជាមួយគ្នានេះដែរ កសិករបានជួបប្រទះនឹងគ្រោះធម្មជាតិ បានបណ្តាលឱ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំស្រូវសរុបចំនួន២៥.៧៨២ហ.ត។

ជាលទ្ធផលជាក់ស្តែង ផលិតកម្មដំណាំស្រូវក្នុងឆ្នាំ២០១៥-២០១៦ អនុវត្តបានលើផ្ទៃដី៣.០៥១.៤១២ហ.ត ផ្ទៃដីអាចប្រមូលផលបានមានចំនួនប្រមាណ៣.០២៥.៦៣០ហ.ត និងបរិមាណផលសរុបទទួលបានចំនួន៩.៣៣៥.២៨៤តោន។ ទិន្នផលមធ្យមប្រចាំឆ្នាំ២០១៥ ទទួលបានចំនួន៣,០៨៥តោន/ហ.ត។ អតិរេកស្បៀងគិតជាអង្ករមានចំនួនប្រមាណ ២.៩៧៥.៨០៩តោន ឬស្មើនឹង៤.៦៤៩.៧០២តោនស្រូវ។

រីឯលទ្ធផលនៃការបង្កបង្កើនផលស្រូវវស្សានិងប្រាំងសម្រាប់ឆ្នាំ២០១៥-២០១៦មានលម្អិតដូចខាងក្រោម៖

- **ការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៥**
  - ផ្ទៃដីភ្ជួររាស់សរុបចំនួន៣.០៧៥.៣៤១ហ.ត លើសឆ្នាំមុនចំនួន៩៥.២២៤ហ.ត
  - ផ្ទៃដីសាបសរុបចំនួន៧០.១២១ហ.ត តិចជាងឆ្នាំមុនចំនួន៤៣.២៤១ហ.ត
  - ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៥៦១.៩៥៧ហ.ត ស្មើនឹង៩៩,៨០% នៃផែនការ២.៥៦៧.១៣០ហ.ត តិចជាងឆ្នាំមុនចំនួន២.៦១៥ហ.ត រួមមាន៖
    - ស្រូវស្រាលចំនួន៥៨៥.៣៤៥ហ.ត តិចជាងឆ្នាំមុន៧៥.៧៦១ហ.ត
    - ស្រូវកណ្តាលចំនួន១.៣១២.៨៤៣ហ.ត លើសឆ្នាំមុន៥៦.៥៨៤ហ.ត
    - ស្រូវធ្ងន់ចំនួន៥៨០.២២៧ហ.ត លើសឆ្នាំមុន២៩.៦៤៧ហ.ត
    - ស្រូវចម្ការចំនួន៣៦.៧៨៣ហ.ត តិចជាងឆ្នាំមុន៧.៣០៥ហ.ត
    - ស្រូវឡើងទឹកចំនួន៤៦.៧៥៨ហ.ត តិចជាងឆ្នាំមុនចំនួន៥៧.៨០៣ហ.ត។
  - ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីសរុបចំនួន២.៥៣៦.១៧៥ហ.ត តិចជាងឆ្នាំមុនចំនួន១.៨០១ហ.ត ដោយទទួលបានបរិមាណផលប្រមាណ៧.១៧០.៦៨៤តោន លើសឆ្នាំមុនចំនួន២៧.១៦៣តោន។ ទិន្នផលជាមធ្យម២,៨២៧តោន/ហ.ត។
- **ការងារបង្កបង្កើនស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦**
  - ផ្ទៃដីអនុវត្តបានចំនួន៤៨៩.៤៥៥ហ.ត តិចជាងឆ្នាំមុន១.៤៨០ហ.ត
  - ផ្ទៃដីប្រមូលផលសម្រេចបានចំនួន៤៨៩.៤៥៥ហ.ត តិចជាងឆ្នាំមុនចំនួន១.៤០៥ហ.ត
  - បរិមាណផលទទួលបានចំនួន២.១៦៤.៦០០តោន តិចជាងឆ្នាំមុន១៦.២៩៦តោន
  - ទិន្នផលទទួលបានប្រមាណ៤,៤២២តោន/ហ.ត។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៩៣១.៥៨១ហ.ត តិចជាងឆ្នាំមុនចំនួន២២.០១៦ហ.ត និងទទួលបានបរិមាណផលសរុបចំនួន១៥.០៦៥.១៨៦តោន លើសឆ្នាំមុនចំនួន៣៣៧.៩២៣តោន ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន៧៩៦.៥០០ហ.ត និងបរិមាណផលចំនួន១៤.២០៧.៩២៨តោន

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១៣៥.០៨១ហ.ត ទទួលបានបរិមាណសរុបចំនួន៨៥៧.២៥៨តោន។

ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្មនិងផលិតភាពមានការកើនឡើងព្រមគ្នា ដែលនេះឆ្លុះបញ្ចាំងពីការវិវត្តជាវិជ្ជមាននៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម តាមរយៈការធ្វើប្រពលវប្បកម្ម ដោយប្រើបច្ចេកទេសសមស្រប និងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវបានពង្រឹង។

### ១.៣ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជារយៈពេល៤ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន២០១.៧៧០តោន ដែលមានការកើនឡើងចំនួន៥៨៧តោន(+០,៣%) លើសបរិមាណនាំចេញរយៈពេល៤ខែដើមឆ្នាំ២០១៥ ដែលមានតែ ២០១.១៨៣តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែមេសានេះមានចំនួន៣៩.៥៥០តោន ដែលមានការថយចុះ១២.១៦៩ តោន(-៣០,៨%) តិចជាងខែមេសា ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន៤៧ប្រទេស ក្នុងនោះ ប្រទេសចិន ឈរលំដាប់ទី១(៤៣.២០៩តោន) ប្រទេសបារាំងឈរលំដាប់ទី២(២៥.៨៥៧តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣(២២.៩៩១ តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤(១១.៣៦១តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥(១០.១៣៧តោន) ប្រទេសបែលហ្ស៊ិក ឈរលំដាប់ទី៦(៩.៦១៧តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧(៩.៤២៦តោន) ប្រទេសឆេកឈរលំដាប់ទី៨(៨.០៣៣តោន) ប្រទេសហុងគ្រីឈរលំដាប់ទី៩(៧.៥៥៨តោន) និងប្រទេសអ៊ីតាលីឈរលំដាប់ទី១០(៧.៥១២តោន)។

## ២ ផ្នែកកៅស៊ូ

ក្នុងឆ្នាំ២០១៥ ផ្ទៃដីចៀរជ័រអនុវត្តបានមានចំនួនជាង១១១.០០០ហិកតា កើនឡើងប្រមាណ២២% បើធៀបនឹងឆ្នាំមុន។ បរិមាណផលិតផលកៅស៊ូសម្រេចបានប្រមាណ១២៦.០០០តោន កើនឡើងប្រមាណ៣០% បើធៀបនឹងឆ្នាំ២០១៤ ដែលមានចំនួនតែជាង៩៧.០០០តោន។ ការនាំចេញកៅស៊ូឆ្នាំ២០១៤ សម្រេចបានចំនួនជាង១០០.០០០តោន ហើយនៅឆ្នាំ២០១៥នេះ ការនាំចេញកៅស៊ូសម្រេចបានរហូតដល់១២៨.០០០តោន គឺកើនឡើងប្រមាណ២៧%។ ជាការកត់សម្គាល់ តម្លៃកៅស៊ូមាននិន្នាការធ្លាក់ចុះ ប៉ុន្តែក្រោមកិច្ចសហការជាមួយសមាគម បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលបង្កើតឡើងដោយរដ្ឋាភិបាលនៃប្រទេសទាំង១១ រួមទាំងកម្ពុជាផង យើងសង្ឃឹមថាតម្លៃកៅស៊ូអាចនឹងកើនឡើងវិញ តាមរយៈការរិះរកវិធានការនានាប្រកបដោយស្ថិរភាព និងមាននិរន្តរភាពសម្រាប់ជាប្រយោជន៍ដល់អ្នកដាំកៅស៊ូ។ បន្ថែមលើនេះទៀតនោះ ក្រសួងបានលើកសំណើជូនរាជរដ្ឋាភិបាលជួយសម្រាលបន្ទុករបស់កសិករដាំកៅស៊ូ ក៏ដូចជាក្រុមហ៊ុនចម្ការកៅស៊ូ ដោយសុំកំណត់ការប្រមូលអាករនាំចេញជាថ្មី ហើយរាជរដ្ឋាភិបាលក៏បានសម្រេចចេញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូរួចហើយ។ ដោយឡែក សម្រាប់ខែមេសា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.២០០ដុល្លារក្នុងមួយតោន។

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៧ | ១៧៥ | - |
| | **សរុប I** | **៥០៨** | **៧៥៧** | **១៧៥** | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុគន្ធនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨ | ១៦.០២៨ | ២.៦៣៣ | - |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៩ | ២.៤៩៨ | ៧ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២.១០១ | ១៨២ | - |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.១១១ | ៥.១២១ | ៧៦៣ | - |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៩ | ៨.៦៦១ | ៥៩២ | - |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសេសស៍ (ស្នួល) | ១.៧៤៥ | ៤.៣៦៥ | ២៦៥ | - |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១.៨៨២ | ៣.៣៩០ | ៧០ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ៣.៣២៧ | ៥.៩២៤ | ៩១ | - |

| | | | | | |
|---|---|---|---|---|---|
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦ | ៥.៧៣១ | ៦៥៨ | - |
| សរុប II | | ២៨.២៧៧ | ៥៣.៨១៩ | ៥.២៦១ | - |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥.៧៣៥ | ១៨៤.២៥២ | ៧.៦៦៥ | ៦១៦ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦.៤៩៦ | ១៤៩.៨៥៣ | ២២.៥០០ | ៥.០០០ |
| សរុប III | | ៨២.២៣១ | ៣៣៤.១០៥ | ៣០.១៦៥ | ៥.៦១៦ |
| សរុប I+II+III | | ១១១.០១៦ | ៣៨៨.៦៨១ | ៣៥.៦០១ | ៥.៦១៦ |

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១៥ជាមួយ International Rubber Association ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់ចំពោះកៅស៊ូ Technically Specified Bubber (TSR)
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន១៥ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រក្រុមហ៊ុនឡុង ស្រេង និងកៅស៊ូសន្លឹក
- ស្រង់ទិន្នន័យជ័រគ្រប់ចម្ការពិសោធន៍ និងស្រង់ទិន្នន័យឧតុនិយម
- រៀបចំដីនិងសម្ភារសម្រាប់ការដាំដុះកៅស៊ូឆ្នាំ២០១៦
- វិភាគ DRC ចំនួន០២ដងលើចម្ការពិសោធន៍នីមួយៗ លើវិធីសាស្ត្រខុសៗគ្នា
- លាបថ្នាំរំញោច លើចម្ការពិសោធន៍ចំនួន១៤ និងវាស់ទឹកជ័រតាមចម្ការពិសោធន៍នីមួយៗ
- ចុះទៅចម្ការកៅស៊ូក្រែក ខេត្តត្បូងឃ្មុំ ដើម្បីស្រង់ទិន្នន័យជំងឺ Oidium ក្នុងឡូត៍ពិសោធន៍ KRAA01-KRAA05។

# ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត រៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** ប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។
- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ន។ នៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ កែប និងពោធិ៍សាត់សម្រេចបាន១៣២ឡ (គិតត្រឹមខែមីនា ឆ្នាំ២០១៦) និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបានចំនួន២៥០ឡ។
- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

## ៣.២ ការងារបសុពេទ្យបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖**

រាជធានី-ខេត្តចំនួន១៣ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន២.០២២លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន១៧,៧គីឡូក្រាម និងផាកពិន័យជាទឹកប្រាក់ចំនួន៦.៥០០.០០០រៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្ដារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។

- ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន១៤១កន្លែង ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត-ក្រុង | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាដ | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្ដុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | | | | |
| ២ | កណ្ដាល | ២២ | | | | | |
| ៣ | កំពង់ស្ពឺ | ១១ | | ៦៣៩ | | ២.៨៥១ | |
| ៤ | ព្រៃវែង | ១១ | | ២៩៧ | ២ | ២.៩១៨ | |
| ៥ | ស្វាយរៀង | ០៨ | | | | | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ០៦ | | ២៤១ | ១៣ | ១.៨៥២ | |
| ៨ | បាត់ដំបង | ១៤ | | | | | |
| ៩ | បន្ទាយមានជ័យ | ១០ | | | | | |
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | ២.២៥៣ | ១៩៦ | ៦.៣៦០ | |
| ១២ | ព្រះសីហនុ | ៣ | | ៧២ | ៤ | ៧៩៨ | |
| ១៣ | កែប | ១ | | ៣៩ | ០ | ៦៩៤ | |
| ១៤ | កំពត | ៥ | | ២៥៦ | | ២.២០៨ | ១.០០០ |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | ៤៧៧ | ២០ | ២.៩៩៤ | |
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | | | | |
| ១៩ | មណ្ឌលគិរី | ២ | | | | | |
| ២០ | ប៉ៃលិន | ១ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២២ | តាកែវ | ០ | ១៨ | | | | |
| ២៣ | កំពង់ចាម | ០ | | ៥០៤ | | ៣.១១៥ | ៣.៦០៤ |
| ២៤ | ត្បូងឃ្មុំ | ០ | | | | | |
| ២៥ | ព្រះវិហារ | ០ | | | | | |
| សរុប | | ១៤១ | ១៨ | ៤.៧៧៨ | ២៣៥ | ២៣.៧៩០ | ៤.៦០៤ |

• **ការងារនីតិកម្មនិងវិវាទះ** ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ហើយក្រសួងកំពុងរៀបចំបោះពុម្ពផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំអត្ថបទក្រោមច្បាប់តាមអាទិភាព។

### ៣.៣ ការងារស្រាវជ្រាវៈ

• **ការងារស្រាវជ្រាវបសុព្យាបាលៈ** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ជាក់ស្តែងក្នុងខែមេសា ឆ្នាំ២០១៦នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន១.៦១៥វត្ថុវិភាគ។

• **ការងារស្រាវជ្រាវផលិតកម្មៈ** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៥៧ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣២ក្បាល គោជំទង់៣២ក្បាល គោបៅដោះ៤៧ក្បាល គោកំផែងសែន៤៣ក្បាល គោកើតថ្មី១ក្បាល គោងាប់២ក្បាល គោលក់២ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២២២ក្បាល ក្នុងនោះជ្រូកបាចំនួន៤ក្បាល ជ្រូកមេ៦១ក្បាល កូនជ្រូក៨៥ក្បាល មេជ្រូកត្រៀមលក់ចំនួន១៥ក្បាល កូនជ្រូកលក់៣៨ក្បាល កូនជ្រូកងាប់ចំនួន៩ក្បាល ជ្រូកថែមថ្មីចំនួន៥៥ក្បាល និងជ្រូកបម្រុង១៤ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេសៈ** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។ គួរកត់សម្គាល់ថា តំបន់មួយចំនួននៃបណ្តាខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល សៀមរាប បាត់ដំបង និងខេត្តស្ទឹងត្រែង បាននិងកំពុងប្រឈមនឹងការខ្វះចំណីសត្វ និងខ្វះទឹក ដែលជាកត្តាធ្វើឱ្យសត្វស្រេស ថមថយសុខភាព ឈឺ និងស្លាប់ សរុបប្រមាណ១៩៩ក្បាល ដែលភាគច្រើនជាសត្វគោ-ក្របី (ក្នុងនោះនៅខេត្តកំពង់ស្ពឺ៥៦ក្បាល ខេត្តកំពង់ធំ៤៧ក្បាល ខេត្តកណ្តាល១០ក្បាល ខេត្តបាត់ដំបង១៨ក្បាល ខេត្តស្ទឹងត្រែង៥៧ក្បាល និងខេត្តសៀមរាប១១ក្បាល)។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០១៦ នៅខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី និងខណ្ឌរដ្ឋបាលព្រៃឈើកំពត ដោយមានប្រវែង ៨២គ.ម

- រៀបចំរបាយការណ៍ការប្រមូលទិន្នន័យធនធានគម្របព្រៃឈើ សម្រាប់ធ្វើការវាយតម្លៃផ្ទៀងផ្ទាត់លទ្ធផលនៃការផលិតផែនទីកាបូនស្តុកព្រៃឈើកម្ពុជា

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តជូនក្រុមហ៊ុន និងអតិថិជនសរុបចំនួន ១៥គ្រឿង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន៤ និងអតិថិជន៣១នាក់ ដែលមានឈើហ៊ីបមូលចំនួន៥.២៧១ម៉ែត្រត្រីគុណ កូនឈើចំនួន១៣៩.៨០៩ដើម អុសចម្រុះចំនួន២១.៨៥០ស្ទែរ និងជ័រទឹកចំនួន១០០តោន។

## ៤.២ ការងារអភិរក្សសត្វព្រៃ

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដោយបានរកឃើញសត្វស្លាបចំនួន២០៦ប្រភេទ ប្រមាណ៩៦.៩៥៦ក្បាល

- ចុះប្រមូលទិន្នន័យ ប្រមូលសំណាកជំងឺសត្វកណ្ដុរដែលស្ថិតនៅភូមិពោធិ៍រោង ឃុំទំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ជាលទ្ធផលប្រមូលបានសំណាកសរុបចំនួន១៦៧សំណាក ពីសត្វកណ្ដុរចំនួន១៤ក្បាល

- ផ្ដល់ ចំណីដល់ត្មាតនៅនៅខេត្តស្ទឹងត្រែង ក្រចេះ ព្រៃការពារមណ្ឌលគិរី និងព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបចំនួន៣៨ក្បាល ការផ្ដល់ចំណីដល់ត្មាតដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការសង្កេតតាមដាន

- ធ្វើការកត់ត្រា និងការពារសម្បុកសត្វត្មាតចំនួន១សម្បុក រំពេទន្លេចំនួន១៣សម្បុក ត្រយ៉ងចង្កំកសចំនួន១៤សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ ។ ការពារសម្បុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសម្បុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ ហើយប្រភេទសត្វទាំងនេះជាប្រភេទជិតផុតពូជ ព្រមទាំងចុះអន្តរាគមន៍ជួយដល់ប្រជាពលរដ្ឋដែលទទួលរងការបំផ្លិចបំផ្លាញដោយសត្វដំរីលើផលដំណាំចំនួន៤ករណីដែលមាន១២គ្រួសារ និង២ក្រុមហ៊ុន ទទួលរងការខូចខាតផលដំណាំមួយចំនួនរួមមាន ចេកចំនួន១៣៥ដើម ស្វាយចន្ទីចំនួន៩ដើម ស្វាយ៩២ដើម ខ្នុរចំនួន៩ដើម បង្គោលភ្លើងស៊ីម៉ង់ត៍ ៣បង្គោល និងបង្គោលភ្លើងដែក៦បង្គោល។ ក្រុមអភិរក្សក៏បានចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាកលាមកដំរីនៅជួរភ្នំក្រវាញនៅដំណាក់កាលទី៤ ដោយទទួលបានសំណាកលាមកដំរីចំនួន៥៦សំណាក ក្នុងនោះលាមកស្រស់មានចំនួន៥០សំណាក និងលាមកស្រស់បង្គួរមានចំនួន៦សំណាក សម្រាប់យកទៅវិភាគ DNA ដើម្បីកំណត់ចំនួនដំរីព្រៃនៅក្នុងជួរភ្នំក្រវាញ។

## ៤.៣ កសិដ្ឋានចិញ្ចឹម ការបន្ថាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែមេសា ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១៧២ក្បាល សត្វកើតថ្មីចំនួន១៨ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន១៩៨ក្បាល សត្វស្លាប់ចំនួន២១ក្បាល ព្យាបាលសត្វចំនួន៣៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន៩ក្បាល ធ្វើឲ្យសន្លប់ចំនួន៤៧ក្បាល បញ្ចុះសត្វល្អិតចំនួន១២ក្បាល វះកាត់សាកសពសត្វចំនួន៧ក្បាល ចាក់វ៉ាក់សាំងចំនួន៣២៤ក្បាល ជួសជុលទ្រុងសត្វចាស់ចំនួន១៣៤ម² ជួសជុលផ្លូវចំនួន២៥.២០០ម² កាប់ឆ្ការអនាម័យព្រៃចំនួន៣.១០០ម² និងអប់រំផ្សព្វផ្សាយសិស្ស និស្សិតចំនួន២៨៤នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្ដាមចំនួន៥៦.១៧១ក្បាល និងនាំចេញកូនស្វាក្ដាមជំទង់ចំនួន១៦៥ក្បាល។

## ៤.៤ ការងារដាំដើមឈើ

- ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអូរបឹងរូង បានធ្វើការឈូសឆាយដីទំហំ៧៨ហិកតា និងបណ្ដុះកូនឈើសរុបចំនួន២០.០០០ដើម

- ចម្ការឈើដែលមានផ្ទៃដីទំហំ២.១៩៣ហ.ត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ ស្ដារព្រៃឈើទូទាំងប្រទេសដែលកំពុងពង្រឹងការយាមល្បាតដើម្បីទប់ស្កាត់ការរុករានហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ និងទប់ស្កាត់ភ្លើងព្រៃ

- បណ្ដុះកូនឈើគ្រប់ប្រភេទបានចំនួន១២៥.៨៨១ដើម និងចែកជូនប្រជាពលរដ្ឋដាំបានចំនួន៦.៩៣២ដើម

- ក្រុមហ៊ុន ស៊ីងបាយអូថេក ជាដៃគូសហការដាំឈើជាមួយរដ្ឋបាលព្រៃឈើនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបឹងចារ បានធ្វើការឈូសឆាយដីដាំឈើចំនួន១៨០ហិកតា និងបណ្ដុះកូនឈើ៦០០.០០០ដើម

- ក្រុមការងារស្រាវជ្រាវ និងកំណត់អត្តសញ្ញាណសត្វល្អិត Linvasa បានចុះអង្កេតដើមប្រេងខ្យល់ដែលបានដាំនៅតាមបណ្ដាផ្លូវជាតិសំខាន់ៗរួមមានផ្លូវជាតិលេខ៧, ១៣, ៧៣ និង៣០៨ពីភ្នំពេញទៅកាន់ខេត្តក្រចេះ, ផ្លូវជាតិលេខ២៤១ និង៦៦ ពីខេត្តស្ទឹងត្រែងទៅកាន់ខេត្តព្រះវិហារ និងផ្លូវជាតិលេខ៦៤ និង៦ ពីព្រះវិហារទៅកាន់ខេត្តកំពង់ធំ ជាលទ្ធផលក្រុមការងារបានរកឃើញនិងប្រមូលសំណាកចំនួន៥សំណាក រៀបចំចង់ប្លាស្ទិចដាក់សត្វល្អិតLinvasa នៅក្នុងចម្ការ

ប្រេងខ្យល់ក្នុងឃុំព្រះធាតុ ស្រុកត្បូងឃ្មុំតាមបណ្តោយផ្លូវជាតិលេខ៧ ដែលមានទំហំប្រហែលកន្លះហិកតាដែលដុះដោយខ្ទែង ។ ចំពោះសំណាកដែលបានប្រមូលនោះក្រុមការងារបានសម្អាត និងបែងចែកទៅតាមថង់ប្លាស្ទិចនីមួយៗដោយរក្សាទុករយៈពេលពី៤ ទៅ៧ថ្ងៃ ទើបសត្វល្អិតនេះចេញពីទ្រនំស្លឹក។ បន្ទាប់មកក្រុមការងារនឹងយកវាចេញពីថង់ប្លាស្ទិច និងរក្សាទុកក្នុងដបដោយលាយជាមួយទឹក Ethanol ដើម្បីរក្សាទុកវាឱ្យបានយូរមុននឹងបញ្ជូនសំណាកទាំងនោះទៅប្រទេសអូស្ត្រាលីក្នុងគោលបំណងធ្វើការវិភាគទៅលើសត្វល្អិតទាំងនេះ។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាចំនួន១ក្រុមហ៊ុន ដែលមានរានទេវតាចំនួន២.៦០០គ្រឿង
- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន១ក្រុមហ៊ុន ដែលមានបរិមាណសរុប៩៥ម៣ និងឈើបន្ទះក្តារចំនួន២ម៣ ឈើចំណិតស្តើង២ម៣ និងMDF ចំនួន៩១ម៣
- ចុះសិក្សាវាយតម្លៃធនធានឈើម៉ៃសាក់ ចំនួន១ក្រុមហ៊ុន ដែលស្នើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចេញផលិតផលឈើអារកែច្នៃចំនួន៥.០០០ម៣ កាត់ជាកង់ចំនួន១៥.០០០ស្ទេរ និងកម្ទេចឈើចំនួន១៥.០០០តោន
- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលចំនួន១ក្រុមហ៊ុន ដែលមានបរិមាណចំនួន៨១ម៣។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែមេសា ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន៧០០.៩៦៦.៤៨០រៀល និងចំណូលពីសេវាសាធារណៈចំនួន៦០៣.៨៥៩.៣៤១រៀល និង២៩.៧៥០,៣១ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែមេសា ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៧៥ករណី ដោយបញ្ជូនទៅតុលាការចំនួន១៣៤ករណី និងពិន័យអន្តរការណ៍ចំនួន៤១ករណី
- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន២២០ម៣ ឈើអារចំនួន៥៩៨ម៣ ឈើក្រាក់គ្រញូងចំនួន២ម៣ និង១គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន២១៥ក្បាលនិង៥២៨គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៣៦៨ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី
- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រី មកដល់ខែមេសានេះការធ្វើអាជីវកម្មត្រូវបានផ្អាកសកម្មភាពរហូតដល់ខែកញ្ញា។ រីឯលទ្ធផលដែលអនុវត្តបានក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦នេះចំនួន១.០៥០តោន ស្មើនឹង៨,៧៥% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១១.២៣៥តោន
- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន២០.០០០តោន សរុបរយៈពេល៤ខែបានចំនួន៩៨.០០០តោន ស្មើនឹង២៥,៥៨% នៃផែនការ៣៨៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២៧.២៥០តោន
- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន៣.០០០តោន សរុបរយៈពេល៤ខែបានចំនួន២១.០០០តោន ស្មើនឹង១៤,៥៨% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៧.១៥៥តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន៩.០០០តោន សរុបរយៈពេល៤ខែបានចំនួន៣២.៨៥០តោន ស្មើនឹង២៩,៨៦% នៃផែនការ

១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១.១១៥តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន១៤.៥០០តោន សរុបរយៈពេល៤ខែបានចំនួន៤០.០៥០តោន ស្មើនឹង ២៣,១៨% នៃផែនការ១៧២.៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥.០០០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន១១.០០០ក្បាល សរុបរយៈពេល៤ខែបានចំនួន៣៨.៣៥០ក្បាល ស្មើនឹង ១៥,៣៤% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៤.៣៥០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ៦.០០០.០០០កូន សរុបរយៈពេល៤ខែបានចំនួន ៣៨.០០០.០០០កូន ស្មើនឹង២១,១១% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួនប្រមាណ៦.០០០.០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាប អនុវត្តបានចំនួន២.៥០០តោន សរុបរយៈពេល៤ខែបានចំនួន១៩.៧០០តោន ស្មើនឹង ២៤,០២% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១.៨០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន៩៥០តោន សរុបរយៈពេល៤ខែបានចំនួន៣.៤៧៥តោន ស្មើនឹង៤៣,៤៤% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២៧៥តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន៧.០០០.០០០លីត្រ សរុបរយៈពេល៤ខែបានចំនួន១៧.៥០០.០០០លីត្រ ស្មើនឹង៣៥% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៤.៥០០.០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់ អនុវត្តបានចំនួន៧៧០តោន សរុបរយៈពេល៤ខែបានចំនួន៣.៣៥០តោន ស្មើនឹង ២២,៣៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៤៥០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន៥៣០តោន សរុបរយៈពេល៤ខែបានចំនួន២.០៥០តោន ស្មើនឹង៤១,០០% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២០០តោន។

**៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

- សម្រាប់ខែមេសា ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន១៨៨ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន១៧៥ករណី និងសមុទ្រចំនួន១៣ករណី សរុបរយៈពេល៤ខែចំនួន៩៤៦ករណី(ទឹកសាប៩០៩ករណី និងសមុទ្រ៣៧ករណី)

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៣១.២៧៥ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៣.៤៨៦មាត់ បង្គោល/ចម្រឹងចំនួន១៦.០១៦ដើម ឧបករណ៍ឆក់ត្រីចំនួន៣៤គ្រឿង សម្រាស់ចំនួន១៣.៦៤៥ម៉ែត្រក្រឡា និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន១.២៧១គ.ក្រ

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន៥៥វគ្គ ដោយមានអ្នកចូលរួមចំនួន២.៤១៩នាក់ ក្នុងនោះស្រ្តីចំនួន៤៦២នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពខេត្ត។

**៥.៦ ការប្រមូលថវិកា**

- ចំណូលពីវិស័យជលផល សម្រាប់ខែមេសា ឆ្នាំ២០១៦ ចំនួន១០៣.១៥៨.៧៤០រៀល សរុបបានចំនួន ៦៧៤.៥៦៨.៧៤០រៀល ស្មើ២២,៤៩% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៥៧៥.៣៩៩.៧៦០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះតាមដាននិងត្រួតពិនិត្យពិសោធន៍ និងបានធ្វើដំណើការសាងសង់ផ្ទះប្រក់ប្លាស្ទិចនិងពិនិត្យសំណាង់ផ្ទះសំណាញ់ដែលជួរទីតាំងដើម្បីការងារពិសោធន៍នៃការការពារដំណាំបន្លែ នៅខេត្តកំពត និងខេត្តកណ្ដាល
- ចុះអង្កេតខ្សែចង្វាក់ផ្គត់ផ្គង់ផលិតផលដំណាំបន្លែ នៅខេត្តតាកែវ និងខេត្តកំពត
- ចុះដាំពិសោធន៍គម្រោង CSE/2012/077 នៅខេត្តតាកែវ និងខេត្តកំពត
- ចុះតាមដាននិងត្រួតពិនិត្យការងារពិសោធន៍ នៅខេត្តតាកែវ។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្ដល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន០៥ក្រុមហ៊ុន សរុបចំនួន១០១មុខ
- ផ្ដល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន១២ក្រុមហ៊ុន ត្រូវជា១៤ករណី
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន០៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន០២ក្រុមហ៊ុន។

### ៧.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន៨ក្រុមហ៊ុន សរុបចំនួន៣៤សំណាក។

### ៧.៣ ការងារបណ្ដុះបណ្ដាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្ដីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្មខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ
- ធ្វើការបែងចែកសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន៥៥ក្បាល។

### ៧.៤ ការងារអនុវត្តច្បាប់

- ចាត់តាំងក្រុមការងារចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្ម ព្រមទាំងចុះធ្វើអធិការកិច្ចសកម្មភាពធ្វើពាណិជ្ជកម្មសម្ភារកសិកម្ម និងសកម្មភាពដឹកជញ្ជូនសម្ភារកសិកម្មល្មើសច្បាប់តាមបណ្ដាច្រករបៀង រវាងព្រំដែនថៃ និងកម្ពុជា ដូចជាខេត្តពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ
- ពិន័យអន្តរការណ៍ជាប្រាក់ចំពោះក្រុមហ៊ុន ជា ឆាយ ត្រេឌីង ក្រុមហ៊ុន នី លីដា ខូអិលឌីធី ដេប៉ូ ប្រាក់ គឹមហួន ដេប៉ូ ស៊ិម អួន និងដេប៉ូ កែវ វិសិទ្ធ។

## ៨ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៣០ច្បាប់ សរុបចំនួន១៤១១ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៧៧ច្បាប់ សរុបចំនួន១២៣៩ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន៩០ច្បាប់ សរុបចំនួន៤៣៩ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦៨៧ច្បាប់ សរុបចំនួន៣.០៨០ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរ ក្នុងខែចំនួន២១ច្បាប់ សរុបចំនួន២៧៩ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៦ច្បាប់ សរុបចំនួន១៥៤ច្បាប់
- ក្រសួងបានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៨៣៤នាក់ នារីចំនួន១.៤៧២នាក់ ស្មើនឹង២១% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.១៦៨នាក់ ក្នុងនោះនារីចំនួន៩៦៥នាក់ ស្មើនឹង២៣%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៦៦នាក់ ក្នុងនោះនារីចំនួន៦០៧នាក់ ស្មើនឹង២២%
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន៦នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន៣នាក់ និងច្បាប់មាតុភាពចំនួន៣នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៣នាក់
- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០៣នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៨៤រូប នៅប្រទេសចំនួន១៦
- ថ្នាក់ដឹកនាំក្រសួងបានចូលជួបសវនាការជាមួយអង្គទូតនានា ព្រមទាំងអង្គការជាតិនិងអន្តរជាតិជាដៃគូយ៉ាងមមាញឹកផងដែរ
- រៀបចំឯកសារពាក់ព័ន្ធ ASEAN Economic Community Development, ASEAN Secretariat ករណី Training Course on "Devlopment of Safe Food Vaue Chan" in Viet Nam and Traning Course on "Advanced Fertilisation Technology to Increase Crop Production" in Maylasia
- ចុះពិនិត្យវាយតម្លៃការអនុវត្តគម្រោងនានាដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំលិខិតជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួមមាន៖ សំណើពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-សាធារណរដ្ឋកូរ៉េលើកទី៣ ការសុំប្តូរប្រភេទទិដ្ឋាការស្នាក់នៅពីប្រភេទE មកB ជូនអ្នកបច្ចេកទេសជនជាតិចិន៣រូប សំណើសុំការអនុវត្ត "កម្មវិធីសុវត្ថិភាពសុខភាពសកល" របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក និង សំណើសុំផ្តល់កិច្ចអន្តរាគមន៍សម្រួលទិដ្ឋាការជូនមន្ត្រី០១រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី"The Plant Health System Analysis" នៅសហរដ្ឋអាមេរិក។

## ១១ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១១.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន១០២៣នាក់ (ស្ត្រី៣៥៦នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន៧៥៤នាក់(ស្ត្រី២៨២នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២៦៩នាក់(ស្ត្រី៧៤នាក់)។ សាលាបានទទួលនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររងអាហារូបករណ៍) ឲ្យចូលរៀនសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។ ជួបពិភាក្សាជាមួយអគ្គរដ្ឋទូតរងរបស់ចិន និងក្រុមហ៊ុនចិន ដើម្បីសិក្សារកវិធីសាស្ត្រធ្វើឱ្យដំណើរការមន្ទីរពិសោធន៍ដែលបានសាងសង់ចប់ និងកំពុងរៀបចំផែនការនិងសកម្មភាព សម្រាប់ពិធីសម្ពោធមន្ទីរពិសោធន៍ដែលជាជំនួយរបស់ចិន។

### ១១.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៩០៨នាក់(ស្ត្រី៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៥៩នាក់ (ស្ត្រី៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន៤៥៥នាក់(ស្ត្រី១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន១២៥នាក់(ស្ត្រី៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន៤៩នាក់ (ស្ត្រី១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន៣៨នាក់(ស្ត្រី១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា ព្រមទាំងចុះធ្វើការពិសោធន៍ស្រាវជ្រាវលើទីវាលតាមមុខជំនាញនីមួយៗផងដែរ។ បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ ក្នុងនោះកំពុងសហការ ជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងសហការជាមួយអង្គការ OISCA បញ្ជូននិស្សិត ជំនាញក្សេត្រសាស្ត្រចំនួន១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន។ ទំនាក់ទំនងជាមួយអង្គការ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់មន្ត្រីទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសកូរ៉េ។ ទទួលជួបគណៈប្រតិភូកូរ៉េស្តីពីគម្រោងចលនាភូមិថ្មីចំនួន០២លើក ដើម្បីសិក្សាអំពីការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវចលនាភូមិថ្មី សហការជាមួយ DTRA (Defence Threat Reduction Agency) ដើម្បីបើកវគ្គអំពីប៉ារ៉ាស៊ីត សត្វឆ្លង ដល់និស្សិត និងមន្ត្រីជំនាញ។

## ១១.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន៣.៩២៤នាក់(ស្រី១.១៨៧នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្តម ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានធ្វើការផ្លាស់ប្តូរនិស្សិតនិងសាស្ត្រាចារ្យបានចំនួន៤៥នាក់ ក្នុងនោះបញ្ជូនសាស្ត្រាចារ្យចេញទៅបរទេសបាន៤នាក់ និង ទទួលនិស្សិតមកពីអូស្ត្រាលី៣នាក់ គ្រូ១នាក់ និស្សិតសឹង្ហបុរី២៥នាក់ គ្រូ២នាក់ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ១២នាក់ គ្រូ១នាក់មកធ្វើកម្មសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើប្រធានបទ ផ្លិនិកសត្វ និង អភិវឌ្ឍន៍សហគមន៍និងការផ្លាស់ប្តូរភាពជាអ្នកដឹកនាំ ។ សាកលវិទ្យាល័យបានសហការជាមួយធនាគារអេម្រិត បើកសិក្ខាសាលាស្តីពីការរកការងារធ្វើជូននិស្សិត២០០នាក់ និងសហការជាមួយភាគីកូរ៉េ KOPIA បើកសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍វិស័យកសិកម្ម ជូននិស្សិត៦០នាក់។

ជារួម គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្មរួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម តាមរយៈលទ្ធផលនៃអង្គសន្និបាតកសិកម្មបានកត់សម្គាល់ថា រយៈពេល៣ឆ្នាំចុងក្រោយនេះ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងខ្លាំងលើផលិតកម្មកសិកម្ម។ ជាក់ស្តែងនៅឆ្នាំ២០១៥កន្លងទៅនេះ យើងបានទទួលរងនូវបាតុភូតគ្រោះធម្មជាតិ គឺគ្រោះរាំងស្ងួត ដែលជាបច្ច័យអាក្រក់រាំងស្ទះដល់ដំណើរការដាំដុះរបស់កសិករ។ តែទោះជាយ៉ាងនេះក្តី វិស័យកសិកម្មរបស់យើងក៏នៅមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដូចបានរៀបរាប់ខាងលើ រីឯការនាំចេញអង្ករកម្ពុជារយៈពេល៤ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន២០១.៧៧០តោន ដែលមានការកើនឡើងចំនួន៥៨៧តោន(+0,៣%) លើសបរិមាណនាំចេញរយៈពេល៤ខែដើមឆ្នាំ២០១៥ មានតែ២០១.១៨៣តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែមេសានេះមានតែ៣៩.៥៥០តោន មានការថយចុះ១២.១៦៩តោន(-៣០,៨%) តិចជាងខែមេសា ឆ្នាំ២០១៥។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំសារាចរណែនាំបន្ថែមទៀតអំពីការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងរដូវប្រាំង និងសារាចរណែនាំស្តីពីការសង្គ្រោះនិងបង្ការទប់ស្កាត់ជំងឺសត្វដោយសារគ្រោះរាំងស្ងួតផងដែរ។ លើសពីនេះទៀតផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៦នេះ។

## IV- **ទិសដៅអនុវត្តបន្ត**

### **១ ផ្នែកដាំដុះ** :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតចង្រៃជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងត្រៀមលក្ខណៈការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៦ឱ្យបានសម្រេចតាមផែនការ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែន

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- ការត្រៀមលក្ខណៈ និងកិច្ចសហការក្នុងការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័លនៅខេត្តសៀមរាប

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បច្ចុប្បន្ននេះ ដោយមានការធ្លាក់ចុះនៃតម្លៃកៅស៊ូនៅលើទីផ្សារដែលធ្វើឲ្យម្ចាស់ច្បារពូជកៅស៊ូសម្រេចចិត្តដកចេញនូវច្បារពូជរបស់ខ្លួន ហើយកសិករមួយចំនួនទៀតបានកាប់ដើមកៅស៊ូចោលនិងដាំដំណាំផ្សេងៗជំនួសវិញ។ ក្រសួងបានជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

### **២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុស

ច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព

- រៀបចំប្រារព្ធទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិ(វុក្ខទិវា) ដែលត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ នៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។**

**៤ ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវជកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- បន្តកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រៀមរៀបចំពិធីមច្ឆទិវាដែលនឹងប្រព្រឹត្តទៅនៅដើមខែកក្កដាខាងមុខនេះ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ត្រៀមរៀបចំបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ ដើម្បីបម្រើសេវាសាធារណៈឲ្យមានតម្លាភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៨អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល ជាពិសេសការផ្ទេរតំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើចំនួន១៣កន្លែង និងព្រៃផ្តល់ផលចំនួន៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែង ពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**